## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

## កម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2016
## (ប្រធានបទ៖ សេដ្ឋកិច្ច ក្រុមទី៣)

ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦

ឆ្លើយតបតាមការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុន យុវជនកម្ពុជាចំនួន២១ រូបដែលមានចំណាប់អារម្មណ៍ទៅលើវិស័យសេដ្ឋកិច្ច នឹងធ្វើទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនពីថ្ងៃទី២៥ ខែតុលា ដល់ថ្ងៃទី១ខែវិច្ឆិកា ជាមួយយុវជនមកពីបណ្តាប្រទេសអាស៊ានទីម័រខាងកើត និងប្រទេសឥណ្ឌា ក្រោមកម្មវិធីបណ្តាញផ្លាស់ប្តូរសិស្ស និស្សិត និងយុវជន រវាងប្រទេសជប៉ុន និងបណ្តាប្រទេសអាស៊ីបូព៌ា ដែលហៅកាត់ថា JENESYS 2016 ។

កម្មវិធី JENESYS 2016 មានគោលបំណងជម្រុញការយល់ដឹង និងទំនុកចិត្តគ្នាទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និង បណ្តាប្រទេសដែលចូលរួម និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពនាពេលអនាគត។

ក្រុមយុវជននឹងធ្វើទស្សនកិច្ចទៅកាន់ទីក្រុងតូក្យូ និង ខេត្តហ្គូនម៉ា ដើម្បីចូលរួមកម្មវិធីផ្លាស់ប្តូរ ជាមួយស្ថាប័ន និងក្រុមហ៊ុនជាច្រើនទៀត ក្រោមប្រធានបទរង "**ព័ត៌មាន និង បច្ចេកវិទ្យាគមនាគមន៍ទាក់ទងនឹងការដឹកជញ្ជូន**"។ ពួកគេក៏នឹងមានឱកាសធ្វើទស្សនកិច្ចនៅរោងចក្រផលិតសូត្រតុមិអុកា(Tomioka Silk Mill) ដែលបានចុះបញ្ជីបេតិកភណ្ឌពិភពលោកយូណេស្កូឆ្នាំ២០១៤ ព្រមទាំងទទួលបាននូវបទពិសោធស្នាក់នៅ

ជាមួយជនជាតិជប៉ុន និងបទពិសោធអំពីវប្បធម៌ជប៉ុន។ ចំពោះកម្មវិធីលម្អិតមានភ្ជាប់មកជាមួយ។

យើងខ្ញុំសង្ឃឹមថាអ្នកចូលរួមនឹងយល់ដឹងអំពីទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសជប៉ុន និងបណ្តាប្រទេសផ្សេងទៀត ហើយបន្ទាប់ពីត្រលប់មកវិញ ពួកគេនឹងចែករំលែកបទពិសោធរបស់ពួកគេ ទៅកាន់ប្រជាជនកម្ពុជាកាន់តែទូលំទូលាយ។

---

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161*

*Email: info.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*